# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១២

## ជប៉ុនផ្តល់ ៦៥,៧៥០ដុល្លាអាមេរិក សម្រាប់ការកសាងអគារសិក្សា



ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ(*ជំនួយគូសាណូណេ*) រដ្ឋាភិបាលជប៉ុនបានផ្តល់ជំនួយដែលមានទឹកប្រាក់សរុបចំនួន ៦៥,៧៥០ដុល្លាអាមេរិក ដល់អង្គការកម្ពុជាដើម្បីកុមារនិងការអភិវឌ្ឍន៍ សម្រាប់គម្រោងសាងសង់អគារសិក្សាមួយខ្នងក្នុងសាលាបឋមសិក្សាក្បៀត្របូរីក្នុងខេត្តពោធិ៍សាត់។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខានៅថ្ងៃនេះដោយឯកឧត្តម លោក ម៉ាសាហ៊ីរ៉ូ គូរ៉ូគី ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង លោក អ៊ឹង ប៉ូឡា នាយកប្រតិបត្តិអង្គការកម្ពុជាដើម្បីកុមារ និងការអភិវឌ្ឍន៍នៅស្ថានទូតជប៉ុន។

ដើម្បីកែលម្អបរិស្ថានអប់រំ អង្គការកម្ពុជាដើម្បីកុមារនិងការអភិវឌ្ឍន៍ដែលជាអង្គការក្នុងស្រុកមួយនៅប្រទេសកម្ពុជា នឹងអនុវត្តគម្រោងសាងសង់អគារសិក្សាថ្មីមួយខ្នងមាន៥បន្ទប់ រួមទាំងបំពាក់បរិក្ខារសិក្សានៅសាលាបឋមសិក្សាក្បៀត្របូរី ក្នុងស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ ជាផ្នែកមួយនៃគម្រោងនេះផងដែរ បន្ទប់ទឹកដែលមាន២បន្ទប់រួមទាំងអាងទឹកនឹងត្រូវបានសាងសង់ផងដែរ។ យើងរំពឹងថា សិស្សានុសិស្សជាង៣០០នាក់នឹងអាចទទួលបានអត្ថប្រយោជន៍ពីការកែលម្អបរិស្ថានអប់រំនេះ។

កម្មវិធីគម្រោងជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ(*ជំនួយគូសាណូណេ*) របស់រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩១ដើម្បីគាំទ្រដល់កិច្ចខំប្រឹងប្រែងរបស់កម្ពុជាដើម្បីនៅក្នុងការអភិវឌ្ឍន៍ និងស្តាបនាប្រទេសឡើងវិញនៅកំរិតមូលដ្ឋាន។ ជំនួយនេះមានគោលបំណងការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជីវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង៤៧លានដុល្លាអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន ៤៦២នៅទូទាំងប្រទេស។



*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*

*អ៊ីមែល: eco.jpn@.pp.mofa.go.jp*

*គេហទំព័រ: http://www.kh.emb-japan.go.jp*